# ក.៣. ជំងឺសំខាន់ៗ

# ជំងឺប្លាស

## ក.៣.១. Blast (*Pyricularia grisea*)



(រូបភាព ១០០) ជំងឺប្លាសកើតនៅលើស្លឹក

**ការពណ៌នា** : ជំងឺនេះបង្កឡើងដោយមេរោគផ្សិត *Pyricularia grisea* ។

ជំងឺប្លាសកើតលើស្លឹក : នៅលើស្លឹកដែលកើតជំងឺមានស្នាមអុចរាងពងក្រពើ ឬប្ញូនជ្រុង ឬក៏រាងស្រួចទ្រវែង ដែលផ្នែកកណ្ដាលនៃស្នាមនេះមានពណ៌សប្រផេះ និងនៅតាមជាយរបស់ស្នាមមានពណ៌ត្នោត ។ ក្នុងដំណាក់កាលធ្ងន់ធ្ងរស្លឹកប្រែក្លាយជាក្រៀមស្វិត ។

ជំងឺប្លាសកើតនៅលើទងស្លឹក : ដំបៅកើតនៅត្រង់ម្តុំតំណស្លឹក និងស្រទបស្លឹក ។ ក្នុងដំណាក់កាលធ្ងន់ធ្ងរវាអាចបណ្ដាលឱ្យស្លឹកងាប់ ។

ជំងឺប្លាសកើតនៅលើថ្នាំងរបស់ដើម : ថ្នាំងដែលកើតជំងឺ មានពណ៌ក្រម៉ៅនិងក្រៀមស្វិត ។

ជំងឺប្លាសកើតនៅលើទងគ្រាប់ : ទងគ្រាប់ដែលកើតជំងឺមានពណ៌ស ស្វិត ហើយងាប់មុនពេលធ្វើការដាក់គ្រាប់ ។

ជំងឺប្លាសកើតនៅកក្ងួរស្រូវ : នៅត្រង់ថ្នាំងនៃកក្ងួរស្រូវមានពណ៌ក្រម៉ៅស្ងួតក្រៀមស្វិត ។ កួរស្រូវដែលកើតជំងឺមានគ្រាប់ស្កក ឬក៏មានគ្រាប់មិនពេញ ។



(រូបភាព ១០១) ជំងឺប្លាសកើតនៅលើទងស្លឹក

**កត្តាដែលធ្វើឱ្យជំងឺកើតឡើង** :

- ប្រើប្រាស់គ្រាប់ពូជដែលមានជំងឺ ឬឆ្លងជំងឺ ។
- ប្រើប្រាស់ជីអាសូតហួសកំរិត ។
- ខ្វះខ្យល់បក់ ឬខ្វះពន្លឺថ្ងៃជះចូលឱ្យបានគ្រប់គ្រាន់នៅតាមដើម ។
- ភ្លៀងនៅពេលថ្ងៃ ហើយសំណើមប្រចាំថ្ងៃខ្ពស់ ។
- មេឃស្រទុំ ភ្លៀងធ្លាក់ញឹកញាប់ និងភ្លៀងរលឹម ។



(រូបភាព ១០២) ជំងឺប្លាសកើតនៅលើថ្នាំងរបស់ដើម



(រូបភាព ១០៣) ជំងឺប្លាសកើតនៅលើទងគ្រាប់



(រូបភាព ១០៤) ជំងឺប្លាសកើតនៅលើករបស់កួរស្រូវ

**ដំណាំជម្រក** : ស្រូវ និង រុក្ខជាតិដទៃទៀត ។

# ជំងឺលោកស្លឹកដែលបង្កឡើងដោយបាក់តេរី

## ក.៣.២. Bacterial Leaf Blight (*Xanthomonas oryzae* pv. *oryzae*)




(រូបភាព ១០៥) ដំណក់ទឹកសន្សើមនៅពេលព្រឹកព្រលឹមនៅត្រង់កន្លែងដែលកើតជំងឺ មានសភាពដូចទឹកដោះគោ ឬពណ៌ល្អក់



(រូបភាព ១០៦) ជាយស្លឹកស្វិតក្រៀម

**ការពណ៌នា :**

ជំងឺនេះបង្កឡើងដោយបាក់តេរី *Xanthomonas oryzae* pv.*oryzae* ។ ស្លឹកដែលកើតជំងឺមានស្នាមពណ៌លឿងនៅតាមបណ្ដោយជាយស្លឹក ។ ពេលដែលស្នាមនៃជំងឺនេះរីករាលដាលកាន់តែធំ ស្លឹកចាប់ផ្ដើមក្រៀមស្វិត ឯជាយស្លឹកវិញមានសភាពដូចទឹករលក ហើយស្លឹកអាចងាប់ ។ លក្ខណៈពិសេសក្នុងការសំគាល់ ជំងឺប្រភេទនេះ គឺថានៅពេលព្រឹកព្រលឹម ពិសេសនៅពេលមានសន្សើមច្រើន នៅលើស្នាមដំបៅមានដំណក់ទឹកល្អក់ពណ៌លឿងស្រអាប់ ។



(រូបភាព ១០៧) ស្លឹកស្វិតរមូរចូលគ្នា ប្រែពណ៌ពីបៃតងព្រលែងទៅពណ៌លឿង

**ការបំផ្លាញ :** ធ្វើឱ្យស្លឹកស្វិតងាប់ ។

**កត្តាដែលធ្វើឱ្យជំងឺកើតឡើង :**

- វត្តមានរបស់ស្មៅនៅក្នុងវាលស្រែ ឬនៅជុំវិញស្រែ ។
- វត្តមានរបស់គល់ជញ្ជ្រាំងដែលមានជំងឺ ។
- វត្តមានរបស់មេរោគនៅក្នុងស្រែ និងនៅក្នុងប្រឡាយទឹក ។
- អាកាសធាតុក្ដៅ សំណើមខ្ពស់ ភ្លៀង និងទឹកនៅក្នុងស្រែច្រើន ។
- ប្រើជីច្រើនហួសកំរិត ។



(រូបភាព ១០៨) កូនសន្ទូងស្វិតងាប់

**ដំណាំជម្រក :** ស្រូវ និង ដំណាំដទៃទៀត ។

# ជំងឺឆ្នូតស្លឹកបណ្ដាលមកពីបាក់តេរី

## ក.៣.៣. Bacterial Leaf Streak (Xanthomonas oryzae pv. oryzicola)



(រូបភាព ១០៩) រូបភាពពីខាងឆ្វេងទៅខាងស្ដាំ បង្ហាញពីការការវិវត្តន៍របស់ជំងឺ

**ការពណ៌នា** : ជំងឺនេះបង្កឡើងដោយបាក់តេរី Xanthomonas oryzae pv. oryzicola ។ នៅពេលទើបនឹងកើតជំងឺ ស្លឹកមានពណ៌បៃតងចាស់ និងមានស្នាមជាំនៅតាមចន្លោះសរសៃស្លឹក ។ ស្នាមជាំនេះរីករាលដាលធំឡើង ហើយប្រែទៅជាពណ៌លឿងប្រផេះ ហើយថ្លាឆ្លុះ និងបន្ទាប់មកវាប្រែទៅជាពណ៌ត្នោត ឬពណ៌សប្រផេះ ហើយក៏ក្រៀមស្វិត ។ ជំងឺនេះច្រើនកើតឡើងចាប់ពីស្រូវចាប់បែកគុម្ព រហូតដល់ស្រូវចេញកួរ ។

**ការបំផ្លាញ** :

- ធ្វើឱ្យស្លឹកឡើងពណ៌ត្នោត និងងាប់ ។
- ធ្វើឱ្យទិន្នផលធ្លាក់ចុះនៅពេលមានការបំផ្លាញខ្លាំង ។



(រូបភាព ១១០) ស្លឹកស្រូវដែលកើតជំងឺ

**កត្តាដែលធ្វើឱ្យជំងឺកើតឡើង** :

- វត្តមានរបស់បាក់តេរីនៅលើស្លឹក ក្នុងទឹក ឬក៏នៅលើសំណល់រុក្ខជាតិនៅក្នុងស្រែក្រោយពេលច្រូតកាត់ ។
- សំណើម និងសីតុណ្ហភាពខ្ពស់ ។

**ដំណាំជម្រក** : ដំណាំដែលនៅក្នុងក្រុម Oryza ដូចជាស្រូវ ។

# ជំងឺទង់គ្រោ

## គ.៣.៤. Tungro



(រូបភាព ១១១) ពណ៌របស់ស្លឹកស្រូវដែលកើតជំងឺ

**ការពណ៌នា :**

ជំងឺនេះចម្លងដោយពពួកសត្វមមាច ជាពិសេស គឺសត្វមមាចខៀវ ។
ដើមដែលកើតជំងឺ បែកគុម្ពតិច ហើយស្លឹកចាប់ផ្តើមប្រែពណ៌ទៅជាពណ៌លឿងពីចុងស្លឹកមកមុន និងមានស្នាមអុចៗពណ៌ច្រែះ ។
ចំណែកឯកួរស្រូវវិញ មិនអាចលេចចេញមកក្រៅបានទាំងស្រុង ឬមិនអាចលេចចេញមកតែម្តង ។ ចំពោះកួរដែលលេចចេញមកក្រៅ គ្រាប់របស់វាស្កក ឬមិនពេញ ។

**ការបំផ្លាញ :**

- ធ្វើឱ្យស្រូវបែកគុម្ពតិច ។
- ធ្វើឱ្យស្រូវមិនអាចផ្កា និងផ្តល់ផ្លែ ។



(រូបភាព ១១២) ស្រូវកើតជំងឺទង់គ្រោ

**កត្តាដែលធ្វើឱ្យជំងឺកើតឡើង :**

- វត្តមានរបស់ភ្នាក់ងារចម្លងជំងឺ និងប្រភពចម្លងជំងឺ ។
- ភាពមិនធន់ទ្រាំរបស់រុក្ខជាតិ ។

**ដំណាំជម្រក :** ស្រូវ និងដំណាំដទៃ ។

# ជំងឺតឿស្មៅ

## គ.៣.៥. Rice Grassy Stunt Virus

**ការពណ៌នា :**

ជំងឺនេះចម្លងដោយមមាចត្នោត ។ ១០ ទៅ ១២ ថ្ងៃក្រោយការចម្លង រោគសញ្ញានឹងចាប់ផ្តើមលេចចេញឡើង ។ ស្រូវដែលកើតជំងឺមានសភាពតឿ បែកគុម្ពច្រើន ដើមដុះត្រង់ទៅលើ ស្លឹកខ្លី ទំហំស្លឹកតូច មានពណ៌លឿងលាយបៃតង មានស្នាម ឬពណ៌ច្រេះតូចៗ ។ ស្រូវដែលកើតជំងឺនេះអាចរស់រហូតដល់ពេលស្រូវទុំ ។



(រូបភាព ១១៣) គុម្ពស្រូវដែលកើតជំងឺ

**ការបំផ្លាញ** : ស្រូវមិនអាចបង្កើតកួរ ។

**កត្តាដែលធ្វើឱ្យជំងឺកើតឡើង :**

វត្តមានរបស់សត្វមមាចត្នោត ។

**ដំណាំជម្រក** : ស្រូវ ។




(រូបភាព ១១៤) គុម្ពស្រូវដែលកើតជំងឺ និងគុម្ពស្រូវដែលមិនឆ្លងជំងឺ

## ក.៣.៦. ជំងឺត្បេញស្លឹក
## Rice Ragged Stunt Virus



(រូបភាព ១១៥) ស្នាមពកនៅតាមសរសៃស្លឹក



(រូបភាព ១១៦) ស្លឹករួញរមួល



(រូបភាព ១១៧) ស្លឹកទង់ជ័យរមួល និងក្បៀបកួរស្រូវ

**ការពណ៌នា :** ជំងឺនេះចម្លងដោយសត្វមមាចត្នោត ។ ដើមដែលកើតជំងឺ មានសភាពតឿនៅដើមដំណាក់កាលនៃការលូតលាស់ ស្លឹកខ្លី មានពណ៌បៃតងចាស់ ជាយស្លឹករួញ និងតួស្លឹករមួល ។ នៅលើស្លឹក និងស្រទបស្លឹកដែលកើតជំងឺ មានស្នាមពកនៅលើសរសៃស្លឹក ។ ស្លឹកទង់ជ័យរមួល និងមានប្រវែងខ្លី ។
ស្រូវមិនអាចផ្កា និងកួរស្រូវមិនអាចលេចមកក្រៅបាន ឬបានតែមួយផ្នែក ។

**ការបំផ្លាញ :** ស្រូវមិនអាចចេញកួរបានទាំងអស់ ឬមិនអាចតែម្តង ។



(រូបភាព ១១៨) កួរស្រូវមិនអាចលេចចេញមកក្រៅបាន

**កត្តាដែលធ្វើឱ្យជំងឺកើតឡើង :**
វត្តមានរបស់សត្វមមាចត្នោត និងដំណាំជម្រករបស់ជំងឺ ។

**ដំណាំជម្រក :** ស្រូវ និងដំណាំដទៃ ។

# ជំងឺរលួយស្រទបស្លឹក

## ក.៣.៧. Sheath Rot (*Sarocladium oryzae*)



(រូបភាព ១១៩) ស្រទបស្លឹកដែលកើតជំងឺ (មើលជិត)



(រូបភាព ១២០) ស្រទបស្លឹកដែលកើតជំងឺ



(រូបភាព ១២១) ស្នាមដំបៅនៅលើស្លឹកទង់ជ័យ

**ការពណ៌នា :**

ជំងឺនេះបង្កឡើងដោយមេរោគផ្សិត *Sarocladium oryzae* ។ ស្រទបស្លឹកដែលកើតជំងឺ មានស្នាមដំបៅពណ៌ប្រផេះនៅផ្នែកកណ្តាល និងពណ៌ក្រហមក្រម៉ៅនៅតាមជាយ ។ ស្រទបស្លឹកប្រែពណ៌ ហើយស្នាមដំបៅរីកចូលគ្នាពេញផ្ទៃស្រទបស្លឹក ។ ករណីធ្ងន់ធ្ងរកួរស្រូវមិនអាចលេចចេញពីស្រទបស្លឹកបាន ។ កួរដែលមិនអាចលេចចេញមកក្រៅបានត្រូវរលួយ ឯចំណែកផ្កាស្រូវវិញប្រែទៅជាពណ៌ក្រហមត្នោត ឬត្នោតចាស់ ។ ចំពោះដើមដែលកើតជំងឺ គេឃើញមានម្សៅពណ៌សកើតមាននៅលើស្រទបស្លឹកផ្នែកខាងក្នុង ។ កួរស្រូវគ្មានគ្រាប់ ស្វិត ឬក៏មានគ្រាប់មិនពេញ ។



(រូបភាព ១២២) កួរស្រូវមិនអាចលេចចេញទាំងស្រុងពីស្រទបស្លឹក



(រូបភាព ១២៣) គ្រាប់ស្រូវដែលកើតជំងឺ

**ដំណាំជម្រក :**

ស្រូវ ពោត និងដំណាំដទៃទៀត ។

**កត្តាដែលធ្វើឱ្យជំងឺកើតឡើង :**

- ស្រូវមានស្នាមរបួសដែលបង្កឡើងដោយការបំផ្លាញរបស់សត្វល្អិត ។
- ប្រើជីអាសូតច្រើនពេក ។
- សំណើមខ្ពស់ ។
- សីតុណ្ហភាព ពី ២០ -២៨ អង្សាសេ ។

**ការបំផ្លាញ :**

- បង្កើតស្នាមដំបៅនៅលើស្រទបស្លឹក ។
- កួរស្រូវគ្មានគ្រាប់ ឬគាប់មិនពេញ ។

# ជំងឺរលាកស្រទបស្លឹក

## ក.៣.៨. Sheath Blight (*Rhizoctonia solani*)



(រូបភាព ១២៤) មើលពីឆ្វេងទៅខាងស្តាំ ដំណាក់កាលនៃការវិវត្តន៍របស់ជំងឺ



(រូបភាព ១២៥) ដើមដែលកើតជំងឺ

**ការពណ៌នា :**

ជំងឺនេះបង្កឡើងដោយមេរោគផ្សិត *Rhizoctonia solani* ។
រោគសញ្ញាដំបូងនៃជំងឺនេះ គឺមានស្នាមដំបៅលើស្រទបស្លឹកក្បែរទងស្លឹក ។ ស្នាមនេះមានរាងពងក្រពើ ឬមូលទ្រវែង ពណ៌បៃតងលាយប្រផេះ ទម្រង់ដូចជាស្នាមជាំ ។ បន្ទាប់មកស្នាម នេះរីកធំដោយមានពណ៌សប្រផេះ នៅផ្នែកកណ្តាល និងមានជាយពណ៌ត្នោត ឬ ពណ៌ត្នោតក្រម៉ៅ ។ ដំបៅរីករាលដាលទៅដល់ស្លឹក ដោយធ្វើមានស្នាមពណ៌ត្នោត ស្រាល និងមានជាយពណ៌ត្នោតចាស់ ។

**ការបំផ្លាញ :**

- បង្កើតជាស្នាមដំបៅនៅលើដើម ស្លឹក និងធ្វើឱ្យស្លឹកងាប់ ។
- ធ្វើឱ្យស្រូវគ្មានផ្លែ ។



(រូបភាព ១២៦) ស្លឹកកើតជំងឺ

**កត្តាដែលធ្វើឱ្យជំងឺកើតឡើង :**

- វត្តមានរបស់មេរោគមាននៅក្នុងដី ។
- សំណើមខ្ពស់ ។
- សីតុណ្ហភាពពី ២៨ ទៅ ៣២ អង្សាសេ ។
- ប្រើជីអាសូតច្រើនហួសកំរិត ។
- វត្តមានរបស់មេរោគអណ្តែតតាមទឹក ។

**ដំណាំជម្រក :** ស្រូវ ពោត ពពួកក្រូច ម្ទេស ពពួកដំណាំក្នុងអំបូរគ្រួយស៊ីហ្វ័រ សណ្តែកសៀង និង ដំណាំដទៃទៀត ។

# ២. ដំណាំផ្លែ

# ២.១.

# រោគសញ្ញា និងការបំផ្លាញ

## ខ.១.១. រោគសញ្ញា និងការបំផ្លាញនៅលើស្លឹក



(រូបភាព ១២៧) ស្លឹកដែលត្រូវបានស៊ីបំផ្លាញដោយដង្កូវហ្វូង ។

→ ដង្កូវហ្វូង (ទំព័រ ៥២)



(រូបភាព ១២៨) ស្លឹកដែលត្រូវបានស៊ីបំផ្លាញដោយដង្កូវហ្វូង ។

→ ដង្កូវហ្វូង (ទំព័រ ៥២)



(រូបភាព ១២៩) កូនដង្កូវហ្វូងរួមជាមួយអាចម៍របស់វានៅលើស្លឹក ដែលវាស៊ីបំផ្លាញ ។ → ដង្កូវហ្វូង (ទំព័រ ៥២)



(រូបភាព ១៣០) ស្នាមស៊ីបំផ្លាញដោយដង្កូវយោលទោង ។

→ ដង្កូវយោលទោង (ទំព័រ ៥៧)



(រូបភាព ១៣១) កូនដង្កូវយោលទោងកំពុងស៊ីបំផ្លាញស្លឹក ។

→ ដង្កូវយោលទោង (ទំព័រ ៥៧)



(រូបភាព ១៣២) ស្លឹកខូចខាតដោយដង្កូវយោលទោង (ស្លឹករបស់ខាត់ណាផ្កា) ។

→ ដង្កូវយោលទោង (ទំព័រ ៥៧)



(រូបភាព ១៣៣) ស្លឹកដែលបំផ្លាញដោយដង្កូវបាក់ខ្នង (ស្ពៃក្តោប)

→ ដង្កូវបាក់ខ្នង (ទំព័រ ៥៥)



(រូបភាព ១៣៤) ស្លឹកដែលស៊ីបំផ្លាញដោយដង្កូវបាក់ខ្នង ។

→ ដង្កូវបាក់ខ្នង (ទំព័រ ៥៥)



(រូបភាព ១៣៥) ដង្កូវស៊ីរូងបណ្តូល ស៊ីស្លឹកដោយមានសំណាញ់ និងអាចម៍របស់វា ។ → ដង្កូវស៊ីរូងបណ្តូល (ទំព័រ ៥៤)



(រូបភាព ១៣៦) ស្លឹកស៊ីបំផ្លាញដោយដង្កូវស៊ីរូងបណ្តូល ។

→ ដង្កូវស៊ីរូងបណ្តូល (ទំព័រ ៥៤)



(រូបភាព ១៣៧) សត្វល្អិតពណ៌ខ្មៅមានឆ្នូតពណ៌សនៅលើស្លាប និងស្នាមប្រហោងតូចៗនៅលើស្លឹក ។ → សត្វទាកតូ (ទំព័រ ៥៨)



(រូបភាព ១៣៨) ស្លឹកដែលស៊ីបំផ្លាញដោយដង្កូវស៊ីត្រួយ ។

→ ដង្កូវស៊ីត្រួយ (ទំព័រ ៥៦)



(រូបភាព ១៣៩) ស្លឹកដែលបំផ្លាញដោយសត្វទាកគូ ។

→ សត្វទាកគូ (ទំព័រ ៥៨)



(រូបភាព ១៤០) កូនស្លឹករបស់ដំណាំស៊ីបំផ្លាញដោយសត្វទាកគូ ។

→ សត្វទាកគូ (ទំព័រ ៥៨)



(រូបភាព ១៤១) ស្លឹករួញកំពឹកកំពក (ស្ពៃចិន) ។

→ ជំងឺម៉ូសាអ៊ិច (ទំព័រ ៦០)



(រូបភាព ១៤២) ស្ពៃរលួយ និងងាប់ (ស្ពៃចិន) ។

→ ជំងឺរលួយទន់ (ទំព័រ ៦១)



(រូបភាព ១៤៣) ស្នាមជាំនៅលើស្លឹក (ស្ពៃក្តោប)

→ ជំងឺរលួយទន់ (ទំព័រ ៦១)



(រូបភាព ១៤៤) ស្នាមអុចដែលមានរង្វង់ពណ៌ត្នោត ឬពណ៌ខ្មៅ (ស្ពៃក្តោប)

→ ជំងឺអុតកង (ទំព័រ ៦២)



(រូបភាព ១៤៥) អុចពណ៌ត្នោតមានស្នាមវណ្ឌ៍នៅផ្នែកខាងក្នុង។

→ ជំងឺអុតកង (ទំព័រ ៦២)



(រូបភាព ១៤៦) ស្នាមអុចៗពណ៌ត្នោតនៅលើផ្ទៃស្លឹក។

→ ជំងឺអុតកង (ទំព័រ ៦២)



(រូបភាព ១៤៧) ស្នាមអុចៗពណ៌ត្នោតនៅលើផ្ទៃស្លឹក (ស្ពៃចិន)។

→ ជំងឺអុតកង (ទំព័រ ៦២)



(រូបភាព ១៤៨) ស្នាមដំបៅពណ៌លឿងលាយជាមួយពណ៌ត្នោត ។

→ ជំងឺផ្សិតសំឡី(ទំព័រ ៦៤)



(រូបភាព ១៤៩) ស្នាមពណ៌លឿងរាយប៉ាយនៅលើផ្ទៃស្លឹក (ស្ពៃក្តោប)។

→ ជំងឺផ្សិតសំឡី (ទំព័រ ៦៤)



(រូបភាព ១៥០) ស្លឹកមានស្នាមដំបៅពណ៌លឿង ឬពណ៌ទឹកក្រូច (ស្លឹកស្ពៃក្ដោប) ។

→ ជំងឺផ្សិតសំឡី (ទំព័រ ៦៤)



(រូបភាព ១៥១) ស្នាមដំបៅ (ស្លឹកស្ពៃក្ដោប) ។

→ ជំងឺផ្សិតសំឡី (ទំព័រ ៦៤)



(រូបភាព ១៥២) ផ្សិតពណ៌សនៅផ្នែកខាងក្រោមស្លឹក (ស្ពៃក្ដោប) ។

→ ជំងឺផ្សិតសំឡី (ទំព័រ ៦៤)



(រូបភាព ១៥៣) ផ្សិតពណ៌សកើតនៅផ្នែកខាងក្រោម ស្លឹកងាប់ (ស្លឹកស្ពៃក្ដោប) ។ → ជំងឺផ្សិតសំឡី (ទំព័រ ៦៤)




(រូបភាព ១៥៤)
ស្នាមពណ៌លឿងដុំៗនៅលើស្លឹក។
→ ជំងឺផ្សិតសំឡី (ទំព័រ ៦៤)

(រូបភាព ១៥៥)
ស្នាមពណ៌លឿងនៅផ្នែកខាងក្រោមនៃស្លឹក។
→ ជំងឺផ្សិតសំឡី
(ទំព័រ ៦៤)





(រូបភាព ១៥៦)
ស្លឹកកើតជំងឺនៅដំណាក់កាលធ្ងន់ធ្ងរ។
→ ផ្សិតសំឡី (ទំព័រ ៦៤)

## ខ.១.២. រោគសញ្ញា និងការបំផ្លាញនៅលើដើម



(រូបភាព ១៥៧) ត្រួយស្ពៃក្រញ្ចាក់ត្រូវបានស៊ីបំផ្លាញ ធាងស្ពៃក្រញ្ចាក់ត្រូវបានស៊ីរូង (ខាត់ណាដើម) ។ → ដង្កូវស៊ីត្រួយ (ទំព័រ ៥៦)



(រូបភាព ១៥៨) ត្រួយស្ពៃក្រញ្ចាក់ និងធាងស្ពៃក្រញ្ចាក់ត្រូវបានស៊ីបំផ្លាញ ។ → ដង្កូវស៊ីត្រួយ (ទំព័រ ៥៦)



(រូបភាព ១៥៩)
ដើមត្រូវបានកាត់ផ្តាច់នៅត្រង់គល់ដើម និងដង្កូវពណ៌ខ្មៅ ។ (ខាត់ណាដើម)
→ ដង្កូវកាត់ដើម (ទំព័រ ៥៣)

(រូបភាព ១៦០) ដើមត្រូវបានកាត់ផ្តាច់នៅត្រង់គល់ ។
→ ដង្កូវកាត់ដើម (ទំព័រ ៥៣)



## ខ.១.៣. រោគសញ្ញា និងការបំផ្លាញនៅលើផ្នែកផ្សេងៗ



(រូបភាព ១៦១) ស្នាមជាំនៅលើផ្កា (ខាត់ណាផ្កា) ។

→ ជំងឺរលួយទន់ (ទំព័រ ៦១)



(រូបភាព ១៦២) ស្នាមជាំរលួយនៅលើផ្កា (ប្រូខូលី) ។

→ ជំងឺរលួយទន់ (ទំព័រ ៦១)



(រូបភាព ១៦៣) ឬសប៉ោងធំ ខុសប្រក្រតី ។

→ ជំងឺឬសត្រមោង (ទំព័រ ៦៣)



(រូបភាព ១៦៤) ដំណាំស្រពោននៅពេលថ្ងៃ (ស្ពៃចិន) ។

→ ជំងឺឬសត្រមោង (ទំព័រ ៦៣)